សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ
PHNOM PENH INTERNATIONAL UNIVERSITY

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រព័ន្ធធានាគុណភាពអប់រំ

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (ស.ភ.ព.អ) ឈរលើគុណភាពអប់រំស្តង់ដាជាតិ និង អន្តរជាតិ រួមបញ្ចូលភាពច្នៃប្រឌិតឌីជីថលនិងការស្រាវជ្រាវនៅក្នុងកម្មវិធីសិក្សា។ ផែនការយុទ្ធសាស្ត្រឆ្នាំ ២០២៥-២០៣០ ផ្តោតសំខាន់លើឧត្តមភាពសិក្សានិងភាពជាដៃគូសកល ការអភិវឌ្ឍធនធានគ្រូបង្រៀនផ្សារភ្ជាប់នឹងបច្ចេកវិទ្យាឌីជីថល និង ការធានានូវគុណភាពនិស្សិតបញ្ចប់ការសិក្សាប្រកបដោយសមត្ថភាពនិងឆ្លើយតបតម្រូវការកម្លាំងពលកម្មសកល។

គោលដៅនៃ "**ការធានាគុណភាពអប់រំ**" នៅតែជាកត្តាចម្បងក្នុងផែនការយុទ្ធសាស្ត្រ ២០២៥-២០៣០។ ការិយាល័យធានាគុណភាពអប់រំផ្ទៃក្នុង (Internal Quality Assurance Unit) បាននិងកំពុងបន្តបេសកកម្មរក្សា និង កសាងវប្បធម៌គុណភាពអប់រំដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ។

ផ្នែកធានាគុណភាពអប់រំផ្ទៃក្នុងរបស់ ស.ភ.ព.អ មានភារកិច្ចដូចតទៅៈ

- ផ្តល់ភាពជាអ្នកដឹកនាំ ភាពច្នៃប្រឌិតប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល និង ស្មារតីក្រុមក្នុងការផ្តល់នូវសេវាកម្មអប់រំប្រកបដោយគុណភាព ស្របតាមស្តង់ដាជាតិ និង អន្តរជាតិ។
- ផ្តល់ការណែនាំ និង លើកទឹកចិត្តដល់គ្រប់ភាគីពាក់ព័ន្ធ (គណៈគ្រប់គ្រង គ្រូបង្រៀន និង បុគ្គលិក ក៏ដូចជានិស្សិត) ក្នុងទំនួលខុសត្រូវការងារ និង ការសិក្សា ដើម្បីសម្រេចបាននូវសមិទ្ធផលប្រកបដោយគុណភាព និងគុណផល។
- បង្កើតទំនាក់ទំនងនិងការប្រាស្រ័យទាក់ទងល្អរវាងការិយាល័យ ដេប៉ាតឺម៉ង់ និង មហាវិទ្យាល័យនៃស.ភ.ព.អ និង ជាមួយស្ថាប័នធានាគុណភាពនៅក្នុងនិងក្រៅប្រទេស។
- ចូលរួមសកម្មក្នុងរាល់សកម្មភាពពាក់ព័ន្ធនឹងការលើកកម្ពស់គុណភាពអប់រំ ការបង្រៀននិងរៀន ការស្រាវជ្រាវ និង សេវាសហគមន៍។
- បន្តថែរក្សាវប្បធម៌គុណភាព និង ការកែលម្អគុណភាពអប់រំជាប្រចាំនៅ ស.ភ.ព.អ។